# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)
# គម្រោងបញ្ចប់ផែនការ
# កំណែលើកទី ២៨
# ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១


**សេចក្តីសង្ខេប** .......... 2
I. **សេចក្តីផ្តើម** .......... 3
II. **វិធានការដែលអាចជួយបញ្ចប់កិច្ចដំណើរការនីតិវិធីបានឆាប់រហ័ស** .......... 6
III. **ផែនការបញ្ចប់ការស៊ើបអង្កេត** .......... 8
ក. ការិយាល័យសហចៅក្រមស៊ើបអង្កេត .......... 8
ខ. អង្គបុរេជំនុំជម្រះ .......... 8
IV. **ផែនការបញ្ចប់សវនាការ** .......... 9
V. **ផែនការបញ្ចប់បណ្តឹងសាទុក្ខ** .......... 9
ក. សំណុំរឿង០០២/០២ .......... 9
ខ. សំណុំរឿង ០០៣ និងសំណុំរឿង ០០៤ .......... 10
VI. **សេចក្តីសន្និដ្ឋាន** .......... 10
ឧបសម្ព័ន្ធ ៖ តារាងកំណត់ពេលវេលាតាមការគ្រោងទុកសម្រាប់ការបញ្ចប់ផែនការ ដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ។


**សម្គាល់៖**
គម្រោងបញ្ចប់ផែនការ អ.វ.ត.ក. ត្រូវបានកែសម្រួលរៀងរាល់មួយត្រីមាសម្តង ក្នុងគោលបំណងរៀបចំផែនការ។ មាតិកានៃគម្រោងនេះ រួមមានការប៉ាន់ប្រមាណនូវពេលវេលាសម្រាប់សំណុំរឿងដែលនៅសេសសល់នៃ អ.វ.ត.ក. គិតត្រឹមពេលនៃការកែសម្រួលនេះ។ កត្តាមួយចំនួន ក្នុងនោះរួមមានការវិវត្តនៃដំណើរការនីតិវិធី គឺអាចមានឥទ្ធិពលទៅលើការប៉ាន់ប្រមាណទុកទាំងនេះ។ ហេតុដូច្នេះ ពេលវេលាដែលគ្រោងទុកទាំងឡាយមិនឆ្លុះបញ្ចាំងតម្រូវការតាមផ្លូវច្បាប់ទៅលើព្រឹត្តិការណ៍សំខាន់ខុសៗគ្នានឹងត្រូវសម្រេចនៅពេលណានោះឡើយ។ គម្រោងបញ្ចប់ផែនការ អ.វ.ត.ក. ត្រូវបានរៀបចំ និងចេញដោយការិយាល័យរដ្ឋបាលដោយមានការចូលរួមយោបល់ពីការិយាល័យតុលាការទាំងអស់។

## សេចក្តីសង្ខេប

គម្រោងបញ្ចប់ផែនការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះ”) ត្រូវបានរៀបចំឡើងជាលើកដំបូងនៅខែមីនា ឆ្នាំ២០១៤ ដោយឆ្លងកាត់ការពិគ្រោះពិភាក្សាយោបល់ពីសំណាក់ការិយាល័យរដ្ឋបាលជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះផ្សេងៗ សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាទាក់ទិននឹងការទទួលខុសត្រូវរបស់ពួកគាត់។ នេះគឺជាការធ្វើបច្ចុប្បន្នភាពប្រចាំត្រីមាសទី២៨ នៃគម្រោងបញ្ចប់ផែនការ ដែលបញ្ចប់នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១[1]។

ក្នុងអំឡុងត្រីមាសនេះ អង្គជំនុំជម្រះតុលាការកំពូលបានជូនដំណឹងភាគីក្នុងសំណុំរឿង ០០២/០២ ថាសវនាការលើបណ្តឹងសាទុក្ខនឹងធ្វើឡើងនៅក្នុងខែឧសភា។ អង្គបុរេជំនុំជម្រះបន្តប្រជុំពិភាក្សាសម្រេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ និង ០០៤។

[1] គម្រោងបញ្ចប់ផែនការដំបូង និងកំណែទាំងអស់អាចរកមើលបានជាសាធារណៈនៅលើគេហទំព័រ អ.វ.ត.ក.។

# I. **សេចក្តីផ្តើម**

1 អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) បានចាប់ផ្តើមដំណើរការរបស់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០០៦ និងបានដំណើរពេញលេញបន្ទាប់ពីការអនុម័ត *វិធានផ្ទៃក្នុង* នៅក្នុងខែមិថុនា ឆ្នាំ២០០៧។ អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីកាត់សេចក្តី “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩”[2]។

2 គម្រោងបញ្ចប់ផែនការនេះបានបរិយាយយ៉ាងលម្អិតដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងបរិបទនៃសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ *A/RES/68/247B* ដែលក្នុងចំណោមបញ្ហាផ្សេងៗទៀតបានកំណត់អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញឲ្យរៀបចំយុទ្ធសាស្រ្តបញ្ចប់ ដោយមានផែនទីបង្ហាញផ្លូវច្បាស់លាស់មួយ។ ឯកសារនេះធ្វើឡើងដោយអង្គជំនុំជម្រះវិសាមញ្ញដោយមានការពិគ្រោះយោបល់តាមរយៈការិយាល័យរដ្ឋបាល ជាមួយចៅក្រមអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាអំពីការទទួលខុសត្រូវរបស់ពួកគេ។ អង្គជំនុំជម្រះវិសាមញ្ញធ្វើបច្ចុប្បន្នភាពផែនការបញ្ចប់នេះរៀងរាល់ត្រីមាស។ ឯកសារនេះគឺជាកំណែលើកទី២៨ ហើយបានបញ្ចូលនូវការកែតម្រូវនានា ដោយផ្អែកលើវឌ្ឍនភាពនៃដំណើរការនីតិវិធីតាមផ្លូវតុលាការដែលកំពុងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ០១ ខែមករា ដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២១។

3 ឯកសារនេះផ្តោតជាពិសេសលើវឌ្ឍនភាពថ្មីៗ នៅក្នុងសំណុំរឿងដែលនៅសេសសល់ទាំងបីដែលបច្ចុប្បន្នកំពុងស្ថិតនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ និងផ្តល់នូវព័ត៌មានអំពីប្រភេទនៃរឿងក្តី ព្រមទាំងស្ថានភាពនៃសំណុំរឿងទាំងនោះ និងជំហាននានាដែលត្រូវបំពេញ មុនពេលកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការបញ្ចប់ជាស្ថាពរតាមផ្លូវច្បាប់។ កិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការក្នុងសំណុំរឿង ០០២ នឹងត្រូវបញ្ចប់នៅពេលមានការវិនិច្ឆ័យស្ថាពរទៅលើសំណុំរឿង០០២/០២[3]។ សហព្រះរាជអាជ្ញាបានថ្លែងជាសាធារណៈថានឹងពុំមានសំណុំរឿងបន្ថែមទៀតទេបន្ទាប់ពីសំណុំរឿង០០៤[4]។ ហេតុដូចនេះសំណុំរឿងដែលមាននាពេលនេះ គឺជាសំណុំរឿងសរុបដែលអង្គជំនុំជម្រះវិសាមញ្ញត្រូវចាត់ការតាមនីតិវិធី។

4 **សំណុំរឿង០០១** ប្រឆាំងនឹង កាំង ហ្កេកអ៊ាវ (ហៅ ឌុច) គឺជាសំណុំរឿងដំបូងដែលបានជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូល បានប្រកាសសាលដីការបស់ខ្លួននៅក្នុងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ធ្វើឲ្យសំណុំរឿងនេះត្រូវបានបញ្ចប់ជាស្ថាពរ។ ជនជាប់ចោទបានទទួលមរណភាពនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ នៅក្នុងមន្ទីរពេទ្យ ខណៈដែលកំពុងតែអនុវត្តទោសដាក់ពន្ធនាគារអស់មួយជីវិត។

5 អង្គជំនុំជម្រះបានបំបែកបទចោទនៅក្នុង**សំណុំរឿង ០០២** ទៅជាសវនាការចំនួនពីរ។ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រម នៅក្នុងសវនាការដំណាក់កាលទីមួយដែលមានឈ្មោះថា សំណុំរឿង

---

[2] *កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣*។

[3] នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចដែលសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុនានាដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ដែលមិនត្រូវបានបញ្ចូលទៅក្នុងសំណុំរឿង ០០២/០១ ឬសំណុំរឿង ០០២/០២៖ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ (ឯកសារ E439/5)។

[4] *សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីៗចំនួន២ ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩។ សេចក្តីថ្លែងការណ៍សាធារណៈដោយសហព្រះរាជអាជ្ញាទាក់ទិននឹងការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ចេញផ្សាយថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១២ និងសេចក្តីថ្លែងការណ៍ដោយសហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងបន្ទុកការងាររបស់ អ.វ.ត.ក. ចេញផ្សាយថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤*។

០០២/០១ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន[5]។ ជនជាប់ចោទចំនួនពីរនាក់ទៀតនៅក្នុងរឿងក្តី គឺ អៀង សារី បានទទួលមរណភាពនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ និង អៀង ធីរិទ្ធ បានទទួលមរណភាពនៅ និងថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥ ហេតុដូចនេះ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងពួកគេត្រូវបានរំលត់។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៧ និងត្រូវបានផ្តន្ទាទោសម្នាក់ៗឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ ដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្នុងសំណុំរឿងនេះត្រូវបានបញ្ចប់នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ដោយមានការប្រកាសសាលដីកាអង្គជំនុំជម្រះតុលាការកំពូល។ អង្គជំនុំជម្រះតម្កល់សាលក្រមសម្រេចផ្តន្ទាទោសអស់មួយជីវិតលើជនជាប់ចោទទាំងពីរ[6]។

6 ការជំនុំជម្រះទីពីរកំពុងដំណើរការក្នុងពេលបច្ចុប្បន្ននេះ ដែលមានឈ្មោះថា សំណុំរឿង ០០២/០២ បានផ្តោតលើជម្រើសតំណាងបទចោទមួយចំនួនដែលនៅសល់ប្រឆាំងនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន។ បទចោទទាំងនេះរួមមានបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លើប្រធានបទដូចជា ការប្រព្រឹត្តិលើជនជាតិចាម និងវៀតណាម សហករណ៍ត្រាំកក់ (រួមបញ្ចូលការប្រព្រឹត្តិលើពុទ្ធសាសនិក) មន្ទីរសន្តិសុខចំនួនបួន ការដ្ឋានចំនួនបួន ការបោសសម្អាតផ្ទៃក្នុង និងបទបញ្ញត្តិស្តីពីការរៀបអាពាហ៍ពិពាហ៍។ សវនាការលើភស្តុតាងបានចាប់ផ្តើមនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ និងបានបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧។ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសង្ខេបផ្ទាល់មាត់ទៅលើសំអាងហេតុ និងសេចក្តីសម្រេចនៃសាលក្រម នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ និងចេញសាលក្រមជាលាយលក្ខណ៍អក្សរជា ០៣ ភាសាផ្លូវការ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។ អង្គជំនុំជម្រះ រកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយបានផ្តន្ទាទោសពួកគេម្នាក់ៗដាក់ពន្ធនាគារអស់មួយជីវិត[7]។ ក្រោយពីទទួលសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា នួន ជា និង ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូង បញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩។

7 នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៩ នួន ជា ទទួលមរណភាពក្នុងអាយុ៩៣ឆ្នាំ ខណៈដែលទទួលការព្យាបាល នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ចប់កិច្ចដំណើរការនីតិវិធី បណ្តឹងសាទុក្ខប្រឆាំងនឹង នួន ជា នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ និងបានបំភ្លឺបញ្ជាក់ថា ពុំមានកិច្ចដំណើរការនីតិវិធីបន្តទៀតអាចធ្វើទៅបានប្រឆាំងនឹង នួន ជា នោះឡើយ។ កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខបន្តទៅក្នុងសំណុំរឿង ០០២/០២ ប្រឆាំងនឹង ខៀវ សំផន តែម្នាក់ប៉ុណ្ណោះ។

8 កិច្ចស៊ើបសួរនៅក្នុង**សំណុំរឿង ០០៣** (ពាក់ព័ន្ធនឹង មាស មុត) និង **សំណុំរឿង ០០៤** បានផ្តួចផ្តើមឡើង ក្រោយពេលសហព្រះរាជអាជ្ញាអន្តរជាតិដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនៅក្នុងឆ្នាំ២០០៩ ហើយបន្ទាប់មកដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ បន្ទាប់មក សហចៅក្រមស៊ើបអង្កេតបានបំបែកសំណុំរឿង ០០៤ ចេញជាសំណុំរឿងចំនួនបី៖ *សំណុំរឿង ០០៤/០១* ពាក់ព័ន្ធនឹង អ៊ឹម ចែម *សំណុំរឿង ០០៤/០២* ពាក់ព័ន្ធនឹង អោ អាន និង សំណុំរឿងដែលនៅសេសសល់ គឺ សំណុំរឿង ០០៤ ប្រឆាំងនឹង យឹម ទិត្យ។

9 នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ ដោយមានសំអាងហេតុលើកលែងចោទប្រកាន់សំណុំរឿង ០០៤/០១ ប្រឆាំងនឹង អ៊ឹម ចែម។ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅមុខអង្គបុរេជំនុំជម្រះ។ នៅថ្ងៃទី

[5] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ (ឯកសារ E313)។
[6] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ (*ឯកសារ F36*)។
[7] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជតក (*ឯកសារ F36*)។

២៨ ខែមិថុនា ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះបានសម្រេចលើបណ្ដឹងឧទ្ធរណ៍លើយុត្តាធិការបុគ្គល ក្នុងនោះរួមមាន នីតិវិធីតុលាការក្នុងសំណុំរឿងនេះផងដែរ។ សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលថា អង្គជំនុំជម្រះវិសាមញ្ញមិនមានយុត្តាធិការលើ អ៊ឹម ចែម ចាត់ទុកជាបានការដែលជាការបញ្ចប់ដំណើរការនីតិវិធីតុលាការក្នុងសំណុំរឿងនេះ[8]។

10 នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា នៅក្នុងសំណុំរឿង ០០៤/០២ ប្រឆាំងនឹង អោ អាន។ អង្គបុរេជំនុំជម្រះបានចេញសេចក្ដីពិចារណារបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ដោយប្រកាសថា អង្គជំនុំជម្រះ "មិនអាចទទួលបានសំឡេងភាគច្រើនលើសលប់នៃសំឡេងគាំទ្រចំនួនបួនតាមការកំណត់ដើម្បីឈានទៅសេចក្ដីសម្រេចផ្អែកលើសំអាងហេតុរួមលើអង្គសេចក្ដីឡើយ"[9]។ សំណុំរឿងប្រឆាំង អោ អាន ត្រូវបានបញ្ជូនទៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ដោយផ្អែកលើមូលដ្ឋានថា ពុំមាន "ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលជាក់លាក់ និងអាចអនុវត្តបាន"[10]។ សំណុំរឿង ០០៤/០២ ត្រូវបាន បង្គាប់ឲ្យបោះត្រា និងដាក់ទៅក្នុងបណ្ណសារនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ដោយបញ្ចប់កិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការលើសំណុំរឿងនេះ[11]។

11 ដំណើរការនីតិវិធីសំណុំរឿង០០៣ និងសំណុំរឿង០០៤ មានវឌ្ឍនភាព ដូចខាងក្រោម៖

ក- នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយចំនួនពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ក្នុងសំណុំរឿង០០៣ ប្រឆាំង មាស មុត។ បណ្ដឹងឧទ្ធរណ៍ចំនួនបីត្រូវបានដាក់ប្រឆាំងនឹងដីកាដំណោះស្រាយ។ មេធាវីការពារក្ដី និងសហព្រះរាជអាជ្ញាជាតិបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។ ចំណែកឯសហព្រះរាជអាជ្ញាអន្តរជាតិប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ[12]។ អង្គបុរេជំនុំជម្រះគ្រោងចេញសាលដីការបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ នៅត្រីមាសទីពីរ ឆ្នាំ២០២១ ដែលនេះជាការពន្យារពេលវេលាលើកទីប្រាំ នៃគម្រោងបញ្ចប់ផែនការនេះ[13]។

ខ- នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ក្នុងសំណុំរឿង ០០៤ ប្រឆាំងនឹង យឹម ទិត្យ។ បណ្ដឹងឧទ្ធរណ៍ចំនួន ០៥ ត្រូវបានដាក់ប្រឆាំងនឹងដីកាដំណោះស្រាយ៖ មេធាវីការពារក្ដី និងសហព្រះរាជអាជ្ញាជាតិបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) សហព្រះរាជអាជ្ញាអន្តរជាតិ និងដើមបណ្ដឹងរដ្ឋប្បវេណីបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាលើកលែងការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ ហើយមេធាវីការពារក្ដី ក៏បានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការចេញដីកាដំណោះស្រាយដោយឡែកពីគ្នាផងដែរ[14]។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ អង្គជំនុំជម្រះបានសម្រេចថា អង្គជំនុំជម្រះនឹងធ្វើការសម្រេចទៅលើបណ្ដឹងឧទ្ធរណ៍ទាំង

[8] សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩/អវតក/កសចស (អបជ៥០) (*ឯកសារ* D308/3/1/20)។
[9] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩/អវតក/កសចស (អបជ៦០) (*ឯកសារ* D359/24-D360/33)។
[10] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩/អវតក/អជសដ/អជតក (*ឯកសារ* E004/2/1/1/2)។
[11] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩/អវតក/កសចស (*ឯកសារ* D363/3)។
[12] ប្រវត្តិនីតិវិធីពេញលេញ អាចរកមើលបាននៅក្នុងគម្រោងបញ្ចប់ផែនការ *កំណែទី២៧*។
[13] *កំណែទី២១* នៃគម្រោងបញ្ចប់ផែនការ រួមបញ្ចូលការព្យាករណ៍រយៈពេលមួយឆ្នាំដំបូងរបស់អង្គជំនុំជម្រះ ជាត្រីមាសទីមួយនៃឆ្នាំ២០២០។ ការព្យាករណ៍នេះត្រូវបានពន្យារលើកទីមួយនៅក្នុង*កំណែប្រែទី ២៣* លើកទីពីរនៅក្នុង*កំណែប្រែទី២៤* លើកទីបីនៅក្នុង*កំណែប្រែទី២៦* និងលើកទីបួននៅក្នុង*កំណែប្រែទី២៧* នៃគម្រោងបញ្ចប់ផែនការ ដោយរយៈពេលមួយត្រីមាសក្នុងពេលពន្យារម្ដងៗ។ អង្គបុរេជំនុំជម្រះបានចេញសេចក្ដីពិចារណារបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៣ នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ (*ឯកសារ D266/27-D267/35*)។
[14] ប្រវត្តិនីតិវិធីពេញលេញមាននៅក្នុង*កំណែប្រែលើកទី ២៧* នៃគម្រោងបញ្ចប់ផែនការ។

នោះ ដោយពុំចាំបាច់មានសវនាការផ្ទាល់មាត់ឡើយ[15]។ អង្គបុរេជំនុំជម្រះព្យាករថានឹងអាចចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងត្រីមាសទី២ ឆ្នាំ២០២១ ដែលបង្ហាញនូវការពន្យារការព្យាករណ៍លើកទី៣[16]។

12 តាមរយៈការវិវត្តក្នុងត្រីមាសចុងក្រោយនេះ គម្រោងបញ្ចប់ផែនការរបស់អង្គជំនុំជម្រះវិសាមញ្ញកំណត់ព្រឹត្តិការណ៍សំខាន់ចំនួនបីសម្រាប់សំណុំរឿងដែលអង្គជំនុំជម្រះបានទទួល។ ព្រឹត្តិការណ៍សំខាន់ដែលនៅសេសសល់ចំនួនពីរនៅក្នុងសំណុំរឿង០០២ និង ការព្យាករណ៍ ដែលពាក់ព័ន្ធគឺ៖

(i) ការចេញសាលដីកាជាភាសាផ្លូវការទាំងបីភាសា (ត្រីមាសទី៤ ឆ្នាំ២០២២)។

13 នៅក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤ ព្រឹត្តិការណ៍ដ៏សំខាន់សរុបចំនួន០២ដាច់ដោយឡែកពីគ្នាត្រូវបានកំណត់សម្រាប់ដំណាក់កាលបណ្តឹងឧទ្ធរណ៍លើកិច្ចស៊ើបសួរ។ ក្នុងករណីសំណុំរឿងត្រូវបានបញ្ជូនទៅជំនុំជម្រះ មានព្រឹត្តិការណ៍សំខាន់បន្ថែមទៀតសម្រាប់ដំណាក់កាលជំនុំជម្រះនិងបណ្តឹងសាទុក្ខ[17]។ ព្រឹត្តិការណ៍សំខាន់សម្រាប់ដំណាក់កាលបណ្តឹងឧទ្ធរណ៍លើកិច្ចស៊ើបសួរដែលបន្តនៅសេសសល់ គឺ៖

(ii) សេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីក្នុងសំណុំរឿងនោះ (ត្រីមាសទី២ ឆ្នាំ២០២១)[18] និង

(iii) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤ ថាតើបញ្ជូនសំណុំរឿងទៅជំម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី២ ឆ្នាំ២០២១)។

## II. វិធានការដែលអាចជួយបញ្ចប់កិច្ចដំណើរការនីតិវិធីបានឆាប់រហ័ស

14 ដំណើរការប្រកបដោយប្រសិទ្ធភាពរបស់អង្គជំនុំជម្រះវិសាមញ្ញកន្លងទៅត្រូវបានរំខាន ដោយភាពមិននឹងនរផ្នែកហិរញ្ញវត្ថុដែលចេះតែបន្តកើតមាន ដែលបណ្តាលឲ្យបុគ្គលិកជាតិធ្វើកូដកម្មមិនធ្វើការចំនួនពីរលើកក្នុងអំឡុងឆ្នាំ២០១៣ ព្រមទាំងបុគ្គលិកចេញចូលពីមុខតំណែងដោយមិនសមហេតុផល។ ការអនុម័តរបស់មហាសន្និបាតទៅលើឧបត្ថម្ភធនសម្រាប់ឆ្នាំសារពើពន្ធ ២០១៤-២០២០ សម្រាប់ភាគីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញ គឺជាវិធានការដ៏សំខាន់ដែលបានធ្វើឲ្យមានស្ថិរភាពដល់ស្ថានភាពថវិកានិងធ្វើឲ្យមានការផ្តោតមូលទៅលើការធ្វើឲ្យវិវត្តទៅមុខនៃអាណត្តិតុលាការ។ ចំពោះភាគីជាតិវិញ ការលំបាកផ្នែកលំហូរសាច់ប្រាក់បាននាំឲ្យមានការពន្យារពេលបើកប្រាក់បៀវត្សសម្រាប់បុគ្គលិកជាតិនៅក្នុងអំឡុងពាក់កណ្តាលឆ្នាំ២០១៥ ដែលប៉ះពាល់ដល់ការផ្តោតអារម្មណ៍ និងទឹកចិត្តបំពេញការងារ។

15 ក្រោយពីមានការសម្តែងនូវការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា មហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងលក្ខណៈជាវិធានការពិសេស បានអនុញ្ញាតឲ្យអគ្គលេខាធិការសម្រេច កំណត់ទឹកប្រាក់ចំនួនមិនលើសពី ៧ លានដុល្លារ នៅក្នុងខែធ្នូ ឆ្នាំ២០២០ ដើម្បីបន្ថែមបង្គ្រប់ធនធានថវិកាស្ម័គចិត្តរបស់ភាគី

---

[15] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩/អវតក/កសចស (ឯកសារ *D381/41-D382/40*)។

[16] *កំណែប្រែទី២១* នៃគម្រោងបញ្ចប់ផែនការ រួមមាន ការព្យាករណ៍រយៈពេលមួយឆ្នាំដំបូងរបស់អង្គជំនុំជម្រះ គឺនៅត្រីមាសទី១ ឆ្នាំ២០២០។ ការព្យាករណ៍នេះត្រូវបានពន្យារ លើកទី១នៅក្នុង*កំណែទី២២* និងលើកទី២ នៅក្នុង*កំណែទី២៤* នៃគម្រោងបញ្ចប់ផែនការ ដែលធ្វើឡើងក្នុងមួយត្រីមាសមួយដង។

[17] ដោយសារស្ថានភាពនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន នៅពេលនេះយើងមិនអាចព្យាករចំណុចពេលវេលាជាក់លាក់ទាក់ទិននឹងគ្រោងការជំនុំជម្រះក្តីបានឡើយ។

[18] អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៣ នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ (*ឯកសារ D266/27-D267/35*)។

អន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញ សម្រាប់រយៈពេលគិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។ គិតមកត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ថវិកាដែលបានផ្តល់ជូនចំនួន ៥០% ឬស្មើនឹង ៣,៥ លានដុល្លា ត្រូវបានប្រើប្រាស់អស់ហើយ ដោយរំពឹងថានឹងមានការចំណាយបន្ថែមទៀត នៅក្នុងអំឡុងឆ្នាំនេះ។ សកម្មភាពទាន់ពេលវេលានេះបានជួយសម្រួលយ៉ាងច្រើនដល់ប្រតិបត្តិការនៅ អង្គជំនុំជម្រះវិសាមញ្ញ មិនឲ្យរអាក់រអួលក្នុងអំឡុងឆមាសទី១ ក្នុងឆ្នាំ២០២១ ដោយបើកឱកាសឲ្យ មានការរៃអង្គាសថវិកាស្ម័គ្រចិត្តបន្តទៀត។ ជាងនេះទៀត ការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្តល់វិភាគទានដោយផ្ទាល់ចំនួន ៣,៦ លានដុល្លារ ដើម្បីចំណាយទៅលើប្រាក់បៀវត្សបុគ្គលិក ជាតិ ០៦ខែដំបូងក៏ដូចជាចំណាយប្រតិបត្តិការសម្រាប់ឆ្នាំ២០២១ គឺជាវិធានការដ៏សំខាន់ដែលជួយដល់ ប្រតិបត្តិការបច្ចុប្បន្នរបស់ភាគីជាតិនៃអង្គជំនុំជម្រះវិសាមញ្ញ។ ដោយរួមបញ្ចូលគ្នាបែបនេះ វិធានការ ទាំងនេះធានាថា ទំហំការងារបច្ចុប្បន្នរបស់អង្គជំនុំជម្រះវិសាមញ្ញ បានបន្តទទួលបាននូវការយកចិត្ត ទុកដាក់ជានិច្ច និងការផ្តល់ថវិកាចាំបាច់។ វិភាគទានស្ម័គ្រចិត្តដែលទទួលបាន ឬដែលបានសន្យា សម្រាប់ឆ្នាំ២០២១ គិតមកត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ មានចំនួន ៣,៦ លានដុល្លារ សម្រាប់ភាគី អន្តរជាតិ និងចំនួន ១,១ លានដុល្លារសម្រាប់ភាគីជាតិ។ ថវិកានេះដើម្បីបង្គ្រប់តាមតម្រូវការថវិកា ដែលបានកែសម្រួលសម្រាប់ឆ្នាំ២០២១ ចំនួន ១២,៩ លានដុល្លារសម្រាប់ភាគីអន្តរជាតិ និង ៤,៩ លាន ដុល្លារសម្រាប់ភាគីជាតិ[19]។

16 នៅខែមករា ឆ្នាំ២០១៥ កិច្ចប្រជុំពេញអង្គរបស់អង្គជំនុំជម្រះវិសាមញ្ញ បានអនុម័តវិសោធនកម្មទៅលើ វិធានផ្ទៃក្នុង ដែលអនុញ្ញាតឲ្យមានការកាត់បន្ថយទៅលើវិសាលភាពកិច្ចស៊ើបសួរ ល្មើកណាវិសាលភាព ស៊ើបអង្កេតដែលបានកាត់បន្ថយជាតំណាងឲ្យបទចោទ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជន សង្ស័យតាមការចោទប្រកាន់[20]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកាត់បន្ថយវិសាលភាពនៃកិច្ច ស៊ើបសួរពាក់ព័ន្ធនឹង មាស មុត ក្នុងសំណុំរឿង០០៣, អោ អាន ក្នុងសំណុំរឿង០០៤/០២ និង យឹម ទិត្យ ក្នុងសំណុំរឿង ០០៤ អនុលោមតាមបទបញ្ញត្តិនេះ។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលា ដំបូងមានសិទ្ធិអំណាច កាត់បន្ថយវិសាលភាពនៃការជំនុំជម្រះក្តីមួយដោយមិនរួមបញ្ចូលអង្គហេតុ ជាក់លាក់មួយចំនួន ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដរាបណាអង្គហេតុដែលនៅ សល់ដែលត្រូវជម្រះ គឺជាតំណាងវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[21]។ ឈរលើមូលដ្ឋាននេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់ កិច្ចនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុដែលមានចែងក្នុងសំណុំរឿង ០០២ ដែលមិនមានបញ្ចូលនៅក្នុងសំណុំរឿង ០០២/០១ ឬសំណុំរឿង ០០២/០២។

17 ការិយាល័យរដ្ឋបាលបានបន្តកិច្ចសន្យាផ្នែកសេវាកម្មរបស់បុគ្គលិកឯកទេសភាសាមួយចំនួន ដើម្បីគាំ ទ្រដល់ការិយាល័យតុលាការទៅតាមការចាំបាច់ ដើម្បីធានាសេវាបកប្រែភាសាបានទាន់ពេលវេលា។

18 ដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ *ការរៀបចំបែបផែនការងារជាជម្រើសផ្សេង* ត្រូវបានដាក់ចេញ អនុវត្តសម្រាប់គ្រប់បុគ្គលិកទាំងអស់នៅ អ.វ.ត.ក. នៅចន្លោះថ្ងៃទី១ និងថ្ងៃទី៥ ខែមករា និងម្តងទៀត ចាប់ពីថ្ងៃទី២៣ ខែកុម្ភៈ រហូតដល់រយៈពេលរាយការណ៍នេះ[22]។ រាល់ធនធានបណ្តាញទាំងអស់ ទាំង

---

[19] *តួលេខថវិកាដែលបានកែសម្រួលសម្រាប់ថវិកាឆ្នាំ២០២០-២០២១ ត្រូវបានគាំទ្រដោយក្រុមបណ្តាប្រទេសដែលមានចំណាប់អារម្មណ៍ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០*។

[20] វិធាន៦៦*ស្ទួន* នៃវិធានផ្ទៃក្នុង។

[21] វិធាន៨៩*ស្ទួន៣* នៃវិធានផ្ទៃក្នុង។

[22] ការរៀបចំទាំងនេះណែនាំដល់បុគ្គលិកទាំងអស់ឲ្យបំពេញការងារពីចម្ងាយ ពីកន្លែងមួយនៅក្នុង ឬខាងក្រៅការិយាល័យ។ សូម មើលគោលការណ៍ណែនាំផ្នែករដ្ឋបាលសម្រាប់ការិយាល័យស្តីពីការរាលដាលនៃជំងឺកូរ៉ូណាថ្មី (កូវីដ-១៩) (កថាខណ្ឌ១៤ និង២២ នៃ *កំណែលើកទី១ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០* និងកថាខណ្ឌ ១៥ និង ២៦ នៃ*កំណែលើកទី៤* បច្ចុប្បន្ន*នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ ២០២០*)។ សម្រាប់ឆ្នាំ២០២០ ការរៀបចំទាំងនេះ ត្រូវបានដាក់ឲ្យអនុវត្តនៅចន្លោះថ្ងៃទី២៥ ខែមីនា និងថ្ងៃទី០១ ខែធ្នូ និងចាប់ ពីថ្ងៃទី០៨ ខែធ្នូ រហូតដល់ដាច់ឆ្នាំ។

ផ្នែករដ្ឋបាល ព្រមទាំងផ្នែកតុលាការ ត្រូវបានផ្តល់ដល់បុគ្គលិកទាំងអស់ពីចម្ងាយ ក្នុងគោលបំណងជួយសម្រួលដល់និរន្តភាពដំណើរការរដ្ឋបាល និងតុលាការ។

## III. ផែនការបញ្ចប់ការស៊ើបអង្កេត

19 ដំណាក់កាលស៊ើបអង្កេតរួមមានយុត្តាធិការរបស់ (ក) ការិយាល័យសហចៅក្រមស៊ើបអង្កេត និង (ខ) អង្គបុរេជំនុំជម្រះនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍។

### ក. *ការិយាល័យសហចៅក្រមស៊ើបអង្កេត*

20 អាណត្តិកំណត់ដោយច្បាប់របស់សហចៅក្រមស៊ើបអង្កេតនឹងត្រូវបញ្ចប់នៅថ្ងៃដូចគ្នានឹងអាណត្តិរបស់អង្គបុរេជំនុំជម្រះដែរ។

### ខ. *អង្គបុរេជំនុំជម្រះ*

21 ក្នុងពេលចាប់ផ្តើមត្រីមាសទី១ ឆ្នាំ២០២១ អង្គបុរេជំនុំជម្រះបានទទួលបណ្តឹងចំនួន ១១ ពោលគឺបណ្តឹងឧទ្ធរណ៍ចំនួន ៤ ក្នុងសំណុំរឿង ០០៣ (បណ្តឹងឧទ្ធរណ៍ចំនួន១ ពាក់ព័ន្ធនឹងការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងឧទ្ធរណ៍ចំនួន ៣ ទៀត ពាក់ព័ន្ធនឹងដីកាដំណោះស្រាយ) សំណើបន្ទាន់បង្ខំចំនួន ០១ និង បណ្តឹងឧទ្ធរណ៍ចំនួន ០៦ (បណ្តឹងឧទ្ធរណ៍ចំនួន ១ ពាក់ព័ន្ធនឹងការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងឧទ្ធរណ៍ចំនួន ០៥ ទៀត ពាក់ព័ន្ធនឹងដីកាដំណោះស្រាយ) ក្នុងសំណុំរឿង ០០៤[23]។ នៅចុងរយៈពេលធ្វើរបាយការណ៍ ញត្តិចំនួន ១១ ខាងលើនេះ នៅតែរង់ចាំការសម្រេចនៅមុខអង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤។

22 អង្គបុរេជំនុំជម្រះមានបំណងសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៣ និង ០០៤ ក្នុងរយៈពេលបួនត្រីមាស ចាប់ពីពេលបណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើសារណាពេញលេញ[24]។ ដើម្បីចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះនឹងត្រូវការពេលវេលាប្រមាណពីរត្រីមាស បន្ទាប់ពីសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[25]។

23 អាស្រ័យលើកាលៈទេសៈនៃបុគ្គលិករបស់អង្គបុរេជំនុំជម្រះ បណ្តឹងដែលពុំបានព្យាករពីមុន ពាក់ព័ន្ធនឹងសំណុំរឿងបច្ចុប្បន្ន និងការបកប្រែបានឆាប់រហ័សលើសេចក្តីសន្និដ្ឋានរបស់ភាគី និងសេចក្តីសម្រេចតុលាការជាបីភាសាធ្វើការទាំងអស់របស់អង្គជំនុំជម្រះវិសាមញ្ញ ការប៉ាន់ស្មាននាពេលបច្ចុប្បន្នមានដូចខាងក្រោម[26]៖

ក. ក្នុង*សំណុំរឿង ០០៣* បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយត្រូវបានធ្វើសារណាពេញលេញនៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៩។ សារណាបន្ថែមត្រូវបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ ដែលត្រូវបានធ្វើសារណាពេញលេញនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០។ ការព្យាករណ៍កែតម្រូវនេះគឺត្រូវចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងត្រីមាសទីពីរ ឆ្នាំ២០២១[27]។ សេចក្តីសម្រេចលើ

---

[23] សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ៣៥)៖ ឯកសារ <u>*D266/2*</u>, <u>*D267/3*</u>, <u>*D267/4*</u>, <u>*D269/3*</u>។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ៦១)៖ ឯកសារ D381/18-D382/21, D381/19, D381/20, D381/29, D382/4/1, D382/22, D384/5។ ឯកសារទាំងអស់ ត្រូវបានអង្គជំនុំជម្រះចាត់ចំណាត់ថ្នាក់ជាឯកសារសម្ងាត់។

[24] ការព្យាករណ៍នេះត្រូវបានប៉ាន់ស្មានឡើងវិញចាប់ពីរយៈពេលពីរត្រីមាស ទៅបួនត្រីមាស នៅក្នុង*កំណែប្រែទី២៤*នៃគម្រោងបញ្ចប់ផែនការ។ សូមមើលក៏ថាខណ្ឌបន្ទាប់សម្រាប់កាលបរិច្ឆេទពាក់ព័ន្ធ។

[25] ការព្យាការណ៍នេះផ្អែកលើបទពិសោធន៍របស់អង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/០២។

[26] ផលប៉ះពាល់នៃជំងឺកូវីដ-១៩ ត្រូវបានអង្គជំនុំជម្រះពិចារណាថាមិនប៉ះពាល់ដល់ការព្យាករណ៍បច្ចុប្បន្នទេ។

[27] អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៣ នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ (*ឯកសារ D266/27-D267/35*)។

បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានវាយតម្លៃឡើងវិញ ដើម្បីចេញនៅត្រីមាសទីពីរ ឆ្នាំ២០២១។

ខ. ក្នុង*សំណុំរឿង ០០៤* បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយបានធ្វើសារណាពេញលេញនៅត្រឹមថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០។ ការគ្រោងទុកដែលមានការកែសម្រួលឡើងវិញគឺថា នឹងមានសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ នៅក្នុងត្រីមាសទី២ ឆ្នាំ២០២១។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចរំពឹងថា យ៉ាងឆាប់បំផុតនឹងចេញនៅត្រឹមត្រីមាសទី៣ ឆ្នាំ២០២១។

## IV. ផែនការបញ្ចប់សវនាការ

24 រហូតដល់មានសេចក្តីសម្រេចចុងក្រោយ របស់អង្គបុរេជំនុំជម្រះ ថាតើសំណុំរឿងទាំងពីរ ឬសំណុំរឿងណាមួយនៃ**សំណុំរឿង០០៣** និង/ឬ **សំណុំរឿង ០០៤** ត្រូវបញ្ជូនទៅជំនុំជម្រះ ទើបអាចមានការប៉ាន់ប្រមាណលើពេលវេលាដែលត្រូវការដើម្បីបញ្ចប់សវនាការទាំងនេះ។ ការវាយតម្លៃទៅលើពេលវេលា ដែលត្រូវការអាចនឹងពឹងផ្អែកលើចំនួនចុងចោទ និងភាពស្មុគស្មាញនៃអង្គហេតុ និងអង្គច្បាប់នៃបទចោទទាំងឡាយដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## V. ផែនការបញ្ចប់បណ្តឹងសាទុក្ខ

### ក. *សំណុំរឿង០០២/០២*

25 នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាបានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមជំនុំជម្រះដោយមានមូលដ្ឋានចំនួនមួយ[28]។ មេធាវីការពារក្តី ខៀវ សំផន បានដាក់បណ្តឹងសាទុក្ខរបស់ខ្លួនជាភាសាបារាំង នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០[29]។ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរបស់ខ្លួនតែមួយភាសា នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ហើយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ចម្លើយតបរបស់ខ្លួនតែមួយភាសានៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១[30]។ ការឆ្លើយតបទៅនឹងចម្លើយតបទាំងនោះនឹងត្រូវបើកសវនាការផ្ទាល់មាត់ដែលគ្រោងនឹងធ្វើឡើងនៅក្នុង ត្រីមាសទី២ ឆ្នាំ២០២១។

26 អង្គជំនុំជម្រះតុលាការកំពូលរំពឹងថា សាលដីកានឹងត្រូវចេញទាំងបីភាសាផ្លូវការនៅត្រឹមត្រីមាសទី៤ ឆ្នាំ២០២២[31]។ ការព្យាករណ៍នេះគឺអាស្រ័យលើភាពស្មុគស្មាញ និងតម្រូវការនៃដំណើរការបណ្តឹងសាទុក្ខ និងកត្តាពាក់ព័ន្ធនានា ដូចជា បុគ្គលិកគ្រប់គ្រាន់ សុខភាព និងសម្បទារបស់ជនជាប់ចោទ ព្រមទាំងសេវាបកប្រែឯកសារទាន់ពេលវេលានិងមានប្រសិទ្ធភាព។

---

[28] សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/អជតក (*ឯកសារ F50*)។ មេធាវីការពារក្តីឆ្លើយតបនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ (សូមមើល *ឯកសារ F50/1*)។

[29] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជតក (*ឯកសារ F54*)។ សំណៅបកប្រែជាភាសាខ្មែរត្រូវបានដាក់នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០។ ពេលវេលាក្នុងការដាក់ឯកសារនេះ និងសំណៅបកប្រែនៃឯកសារនេះ ត្រូវបានពន្យល់យ៉ាងលម្អិតនៅក្នុងគម្រោងបញ្ចប់ផែនការ កំណែទី២៧។

[30] សហព្រះរាជអាជ្ញា៖ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជតក (*ឯកសារ F54/1*)។ សំណៅបកប្រែជាភាសាខ្មែរត្រូវបានជូនដំណឹងនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជតក (*ឯកសារ F54/2*)។ សំណៅបកប្រែជាភាសាខ្មែរ ត្រូវបានជូនដំណឹងនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១។

[31] ផលប៉ះពាល់នៃជំងឺកូវីដ-១៩ ត្រូវបានអង្គជំនុំជម្រះពិចារណាថាមិនប៉ះពាល់ដល់ការព្យាករណ៍បច្ចុប្បន្នទេ។

### ខ. *សំណុំរឿង ០០៣ និងសំណុំរឿង ០០៤*

27 ប្រសិនបើសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ បន្តទៅមុខរហូតដល់ដំណាក់កាលជំនុំជម្រះនោះ បណ្តឹងសាទុក្ខភ្លាមៗ ឬបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងអាចកើតឡើង។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ដោយហេតុថាយើងមិនដឹងថាសំណុំរឿងណាមួយដំណើរការរហូតដល់ដំណាក់កាលជំនុំជម្រះ និងមិនដឹងពីបទចោទណាខ្លះនោះ វាហាក់ដូចជាឆាប់ពេកក្នុងការផ្តល់នូវការប៉ាន់ស្មានចំពោះពេលវេលាដែលតម្រូវ ក្នុងការសម្រេចលើបណ្តឹងសាទុក្ខណាមួយនៃសំណុំរឿងពាក់ព័ន្ធ។

## VI. សេចក្តីសន្និដ្ឋាន

28 សម្រាប់*ឆ្នាំ២០២១* ព្រឹត្តិការណ៍សំខាន់ពីរត្រូវបានរំពឹងទុកគឺ ការចេញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយក្នុង (i) សំណុំរឿង ០០៣ ប្រឆាំង មាស មុត និង (ii) សំណុំរឿង០០៤ ប្រឆាំង យឹម ទិត្យ ថាតើត្រូវបញ្ជូនសំណុំរឿងទាំងនេះទៅជំនុំជម្រះ ឬបញ្ចប់កិច្ចដំណើរការនីតិវិធី។

29 សម្រាប់*ឆ្នាំ២០២២* ព្រឹត្តិការណ៍សំខាន់មួយត្រូវបានរំពឹងទុកគឺ (iii) ការចេញសាលដីកាក្នុងសំណុំរឿង ០០២/០២ ដោយអង្គជំនុំជម្រះតុលាការកំពូល។

30 ប្រសិនបើសំណុំរឿង ០០៣ និង/ឬសំណុំរឿង ០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះទាំងមូល ឬដោយផ្នែក ពេលវេលាកំណត់សម្រាប់សំណុំរឿងទាំងនេះនឹងត្រូវព្យាករនៅពេលនោះ។

31 ព្រឹត្តិការណ៍សំខាន់ៗដែលបានគ្រោងទុក មានបង្ហាញជូនក្នុងតារាងដែលភ្ជាប់ជាមួយនឹងផែនការនេះ។

# តារាងកំណត់ពេលវេលាតាមការគ្រោងទុកដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ

គម្រោងបញ្ចប់ផែនការ កំណែលើកទី ២៨ - ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១

| សំណុំរឿង | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ២០២១ | | | | ២០២២ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ត្រីមាស ១ | ត្រីមាស ២ | ត្រីមាស ៣ | ត្រីមាស ៤ | ត្រីមាស ១ | ត្រីមាស ២ | ត្រីមាស ៣ | ត្រីមាស ៤ | ត្រីមាស ១ | ត្រីមាស ២ | ត្រីមាស ៣ | ត្រីមាស ៤ | ត្រីមាស ១ | ត្រីមាស ២ | ត្រីមាស ៣ | ត្រីមាស៤ | ត្រីមាស១ | ត្រីមាស ២ | ត្រីមាស ៣ | ត្រីមាស ៤ |
| សំណុំរឿង ០០២/០១ ខៀវ សំផន | ដំណាក់កាលជំនុំជម្រះ (ខ) (គ) | | | | | បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម (ឃ) (ង) | | | | | | | | | | | | | | |
| សំណុំរឿង ០០៣ មាស មុត | កិច្ចស៊ើបសួរតាមផ្លូវតុលាការ (ច) (ឆ) | | | | | បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ជ) | | | | | | | | | | | | | | |
| សំណុំរឿង ០០៤ យឹម ទិត្យ | កិច្ចស៊ើបសួរតាមផ្លូវតុលាការ (ច) (ឆ) | | | | | | | បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ (ជ) | | | | | | | | | | | | |

(ក) សេចក្តីថ្លែងបិទកិច្ចពិភាក្សាដេញដោល (មុនឆ្នាំ២០១៨)
(ខ) សាលក្រម៖ សង្ខេប និងផ្នែកសម្រេចសេចក្តី
(គ) សាលក្រម៖ មានសំអាងហេតុ និងជាបីភាសា
(ឃ) កាលបរិច្ឆេទកំណត់សម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម
(ង) សាលដីកា

(ច) ដីកាដំណោះស្រាយពីរផ្ទុយគ្នា តែមួយភាសាប៉ុណ្ណោះ
(ឆ) ដីកាដំណោះស្រាយពីរផ្ទុយគ្នា ជាភាសាខ្មែរ និង អង់គ្លេស
(ជ) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ